ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១១ សសរ

**សេចក្តីសម្រេច**

**ស្តីពី**

**ការបង្កើតគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការតម្លើងនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ទៅជាអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍, តម្លើងនាយកដ្ឋានសហប្រតិបត្តិការ និងគ្រប់គ្រងបំណុល ទៅជាអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល និងបង្កើតនាយកដ្ឋានសវនកម្មបច្ចេកវិទ្យាព័ត៌មាន ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបំណុលសាធារណៈ

- សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៤២.សសរ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

**សម្រេច**

**ប្រការ១.**_

បង្កើតគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈមានសមាសភាព ដូចខាងក្រោម÷

| | | | |
|---|---|---|---|
| ១-ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ | **អូន ព័ន្ធមុនីរ័ត្ន** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២-ឯកឧត្តម | **វង្សី វិស្សុត** | រដ្ឋលេខាធិការប្រចាំការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធានប្រចាំការ |
| ៣-លោកជំទាវ | **នាង ច័ន្ទថាណា** | ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា | អនុប្រធាន |
| ៤-ឯកឧត្តម | **ហែម វណ្ណឌី** | អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៥-លោកជំទាវ | **ស្រី ស៊ីយុត** | អគ្គពិនិត្យ ធនាគារជាតិនៃកម្ពុជា | សមាជិក |
| ៦-លោកជំទាវ | **ជា សិរី** | អគ្គនាយកបច្ចេកទេស ធនាគារជាតិនៃកម្ពុជា | សមាជិក |
| ៧-ឯកឧត្តម | **ម៉ែន ធីរុទ្ធ** | អគ្គនាយក នៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក។ |

**ប្រការ២.**_

គណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ ជាចំណុចប្រមូលផ្តុំរបស់រាជរដ្ឋាភិបាល មានមុខងារ និងភារកិច្ច ដូចតទៅ÷

- រៀបចំ និងត្រួតពិនិត្យការអនុវត្តចក្ខុវិស័យ និងគោលនយោបាយស្តីពីការគ្រប់គ្រងបំណុលសាធារណៈ
- ពិនិត្យយល់ព្រមលើយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ មុននឹងដាក់សុំការសម្រេចពីនាយករដ្ឋមន្ត្រី
- ធ្វើជាសេនាធិការរបស់រាជរដ្ឋាភិបាល ក្នុងការសម្របសម្រួលគោលនយោបាយពាក់ព័ន្ធ ដើម្បីធានាឱ្យមានសង្គតិភាពរវាងកិច្ចដំណើរការគ្រប់គ្រងបំណុលសាធារណៈ ជាមួយនឹងគោលនយោបាយគ្រប់គ្រងហិរញ្ញវត្ថុ, ថវិកា, និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល។

**ប្រការ៣.**_

គណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ ធ្វើការប្រជុំសាមញ្ញរបស់ខ្លួនក្នុងរយៈពេល ៦ (ប្រាំមួយ) ខែម្តងដង តាមការអញ្ជើញរបស់ប្រធាន ឬអាចប្រជុំញឹកញាប់ជាងនេះ ទៅតាមតម្រូវការចាំបាច់នៃការងារ។

**ប្រការ៤.**_

គណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ អាចបង្កើតគណៈកម្មការ ឬក្រុមការងារផ្សេងៗទៅតាមការចាំបាច់ ដើម្បីសម្របសម្រួលការរៀបចំ និងតាមដានការអនុវត្តផែនការសកម្មភាព កម្មវិធីនានា ពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ។

**ប្រការ៥.**_

ប្រធានគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ អាចអញ្ជើញថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនានា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធដែលមិនមែនជាសមាជិកនៃគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ ឱ្យចូលរួមប្រជុំតាមតម្រូវការចាំបាច់នៃការងារ។

**ប្រការ៦.-**

ក្នុងករណីអវត្តមានសមាជិកនៃគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈអាចស្នើសុំការអនុញ្ញាតពីប្រធានគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ ដើម្បីចាត់តាំងមន្ត្រីពាក់ព័ន្ធឱ្យចូលរួមប្រជុំជំនួស។ សមាជិកគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ អាចស្នើសុំការអនុញ្ញាតពីប្រធានគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ ឱ្យមន្ត្រីជំនាញដែលមានការពាក់ព័ន្ធផ្ទាល់ទៅនឹងការងារគ្រប់គ្រងបំណុលសាធារណៈ ចូលរួមប្រជុំក្នុងឋានៈជាមន្ត្រីជំនួយការ។

**ប្រការ៧.-**

គណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ មាននាយកដ្ឋានគ្រប់គ្រងបំណុល នៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាលេខាធិការដ្ឋានបំពេញមុខងារជាសេនាធិការបច្ចេកទេសរបស់ខ្លួនក្នុងការបំពេញការងារ។

**ប្រការ៨.-**

គណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ ប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅក្នុងការបំពេញការងាររបស់ខ្លួន។

**ប្រការ៩.-**

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១០.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*ថ្ងៃអង្គារ ៨កើត ខែ មាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២*

*រាជធានីភ្នំពេញ ថ្ងៃទី១២ ខែ កុម្ភៈ ឆ្នាំ ២០១៩*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ១០
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ